**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ៧៦២នាក់ នៃរោងចក្រទាំង២៦ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឮកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង២៦ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ៣ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៣**

**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**

**ចំនួន ២៦ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 26 |
| 1 | ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ម៉ាស្ទេច អ៊ីនខេម (ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន វី.ធី ហ្គាម៉ិន អេកសេសិរី ខូ អិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហាយ សេង 168(ខេមបូឌា)ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ស៊េង យ៉ុង ហ្គាមែនហ្វាត់តូរី ខូអិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ខេវីធី អ៊ីអឹមប៊ី បេស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ជេ-កូរី បេស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ខេមហ្វអេវើ | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ខេមបូ យូនីសូល អិលធីឌី | កណ្តាល |
| 10 | ក្រុមហ៊ុន ប្រេស្ទីច.ហ្គាម៉ិន.ឯ.ក | កណ្តាល |
| 11 | ក្រុមហ៊ុន វ៉ាយស៍ ស្ទីឌី ហ្វូដវែរ មេធៀរៀល (ខេមបូឌា) ឯ.ក | កំពង់ចាម |
| 12 | ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន(ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ឆាមហ្គោ(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន វីសខត ប្រដាក់ ឯ.ក | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន ហ៊ែនថុន ឡាក់ហ្គេដ (ខេមបូឌា) ឯ ក | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូត វែរ ឯ.ក | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន អិមអេ ហ៊ែនប៉ែក (ខឹមបូឌា)ខូអែលធីឌី | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ស្មាត សាញ ហ្គាម៉ិន(ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ព្រីនអិកស៍ ជីភី (ខេមបូឌា) ហ្វេកធើរី ឯ.ក | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន ចឹងស្រេង អ៊ិនដាសស្ទ្រៀល | តាកែវ |
| 21 | ក្រុមហ៊ុន អ៊ី-ចេង (ខេមបូឌា) ឧបភើរេសិន | តាកែវ |
| 22 | ក្រុមហ៊ុន ជីនឡាយ ថេកស្ថាយ ឯ.ក | ព្រះសីហនុ |
| 23 | ក្រុមហ៊ុន ស៊ុហ្សូ យុនយីង ថេកស្ថាយ(ខេមបូឌា)ខូ អិល ធី ឌី | ព្រះសីហនុ |
| 24 | ក្រុមហ៊ុន ស័ងលី វីន (ខេមបូឌា)ហ្គាម៉ិន | ស្វាយរៀង |
| 25 | ក្រុមហ៊ុន យូលី អ៊ិនធើណេសិនណល(ខេមបូឌា)ហ្គាមេន | ស្វាយរៀង |
| 26 | ក្រុមហ៊ុន ឡេក ស្ព័រ (ខេមបូឌា) អ៊ិនដាសស្ទ្រៀល អ៊ិនវេសម៉ិន ឌីវេឡុបម៉ិន ឯ.ក | ស្វាយរៀង |